**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** :.........១៦៦.........**ក.ប**/ប្រ.ក.ប.ស.ស
២៣

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ ប្រាក់បំណាច់មាតុភាព និងវិភាជន៍បូជាសព ក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ច

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកំណត់ប្រាក់ឈ្នួលឬប្រាក់បៀវត្សជាប់ភាគទាន
- យោងប្រកាសលេខ១៨៤ កប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលប្រការ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព



អាសយដ្ឋាន៖ អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

- យោងប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព

- យោងតាមការចាំបាច់របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលព្យាបាលជំងឺ ប្រាក់បំណាច់មាតុភាព និងវិភាជន៍បូជាសព ក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ចដើម្បីធានាប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការអនុវត្តរបបសន្តិសុខសង្គម។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ៣ .-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម៖

- *ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ* សំដៅដល់ប្រាក់ឧបត្ថម្ភដល់សមាជិក **ប.ស.ស**. សម្រាប់រយៈពេលអាក់ខានការងារដោយសារជំងឺ ឬគ្រោះថ្នាក់ក្រៅពីហានិភ័យការងារ។
- *ប្រាក់បំណាច់មាតុភាព* សំដៅដល់ប្រាក់ឧបត្ថម្ភដល់សមាជិក **ប.ស.ស**. សម្រាប់រយៈពេលនៃការឈប់សម្រាកមុននិងក្រោយសម្រាលកូន។
- *ប្រាក់អវសិដ្ឋ* សំដៅដល់តាវកាលិកដែលខកខានមិនបានទាមទារក្នុងករណីប្រធានសក្តិ។
- *វិភាជន៍បូជាសព* សំដៅដល់ប្រាក់ឧបត្ថម្ភសម្រាប់ការចាត់ចែងបូជាសពសមាជិក **ប.ស.ស**. ដែលទទួលមរណភាព។
- *អ្នកតំណាងជនរងគ្រោះ ឬអ្នកជំងឺ* សំដៅដល់សាច់ញាតិ ឬសហព័ទ្ធរបស់សាមីខ្លួន។

## ជំពូកទី២

## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ

## ផ្នែកទី១

## លក្ខខណ្ឌ

**ប្រការ៤ .-**

សមាជិក **ប.ស.ស**. មានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺលុះត្រាតែ៖

- បានចុះបញ្ជីផ្នែកថែទាំសុខភាព
- កំពុងបំពេញការងារនៅក្នុងសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីនៅ **ប.ស.ស**.
- បានបង់ភាគទាន២(ពីរ)ខែជាប់គ្នា ឬ៦(ប្រាំមួយ)ខែក្នុងរយៈពេល១២(ដប់ពីរ)ខែចុងក្រោយ គិតមកទល់ខែដែលមានជំងឺ ឬគ្រោះថ្នាក់ក្រៅពីហានិភ័យការងារ

- បានអាក់ខានការងារចាប់ពី៨(ប្រាំបី)ថ្ងៃឡើង ដោយសារការសម្រាកព្យាបាលថែទាំជំងឺ ឬរបួសតាមវេជ្ជបញ្ជានៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.**។

## ផ្នែកទី២

## បែបបទ និងនីតិវិធី

**ប្រការ៥ .-**

ការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ ត្រូវធ្វើឡើងដោយអ្នកជំងឺឬជនរងគ្រោះ ឬអ្នកតំណាង តាមរយៈទម្រង់នៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ ដោយត្រូវភ្ជាប់មកជាមួយនូវ៖

- លិខិតអនុញ្ញាតចេញដោយមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.** ដែលជនរងគ្រោះបានទៅទទួលសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ
- លិខិតសុំអនុញ្ញាតច្បាប់ចេញដោយគ្រូពេទ្យសហគ្រាស គ្រឹះស្ថាន ដោយមានការយល់ព្រមពីនិយោជក ឬអ្នកតំណាងសហគ្រាស គ្រឹះស្ថាននោះ
- លិខិតផ្ទេរសិទ្ធិសម្រាប់អ្នកតំណាង
- គណនីធនាគារដៃគូដែលកំណត់ដោយ **ប.ស.ស.**
- ឯកសារចាំបាច់ផ្សេងទៀតតាមការកំណត់របស់ **ប.ស.ស.**។

**ប្រការ៦ .-**

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ ត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃដំបូងនៃការចូលសម្រាកព្យាបាលឡើងទៅ។

ប្រាក់បំណាច់នេះត្រូវផ្តល់ជូនតាមរូបមន្តដូចខាងក្រោម៖

**ប.ប.ព** = **៧០**% × **ប.ឈ.ម** × **ច.ព**

| | |
|---|---|
| **ប.ប.ព** | ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ |
| **ប.ឈ.ម** | ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃដែលបានបង់ភាគទានរបស់សាមីជន |
| **ច.ព** | ចំនួនថ្ងៃឈប់សម្រាកព្យាបាល |

**ប្រការ៧ .-**

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺត្រូវផ្តល់ជូនមិនត្រូវលើសពី១៨០(មួយរយប៉ែតសិប)ថ្ងៃក្នុងរយៈពេល១២(ដប់ពីរ)ខែចុងក្រោយ ដោយគិតចាប់ពីកាលបរិច្ឆេទមានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ។

# ជំពូកទី ៣

# លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប្រាក់បំណាច់មាតុភាព

## ផ្នែកទី១

## លក្ខខណ្ឌ

**ប្រការ៨ .-**

សមាជិក **ប.ស.ស.** ដែលមានគភ៌ចាប់ពី២៦(ម្ភៃប្រាំមួយ)សប្តាហ៍ឡើងមានសិទ្ធិទទួលបានប្រាក់បំណាច់មាតុភាពលុះត្រាតែ៖

- បានចុះបញ្ជីផ្នែកថែទាំសុខភាព

- បានបង់ភាគទានយ៉ាងតិច៩(ប្រាំបួន)ខែក្នុងរយៈពេល១២(ដប់ពីរ)ខែចុងក្រោយ គិតមកទល់កាលបរិច្ឆេទសម្រាលកូន
- បានសម្រាលនៅតាមមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.**។

ករណីសមាជិក **ប.ស.ស.** ទៅសម្រាលកូននៅមូលដ្ឋានសុខាភិបាលដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.** សាមីជនត្រូវទៅពិនិត្យសុខភាពក្រោយសម្រាលនៅមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.** យ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃសម្រាល។

## ផ្នែកទី២
## បែបបទ និងនីតិវិធី

**ប្រការ៩ .-**

ការទាមទារប្រាក់បំណាច់មាតុភាព ត្រូវធ្វើឡើងដោយសាមីខ្លួនឬអ្នកតំណាងតាមរយៈកម្មវិធីសមាជិក **ប.ស.ស.** (NSSF Member APP) ឬតាមរយៈទម្រង់នៃការទាមទារប្រាក់បំណាច់មាតុភាពដោយត្រូវភ្ជាប់មកជាមួយនូវ៖

- លិខិតអនុញ្ញាតដោយមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.** ដែលសាមីខ្លួនបានទៅទទួលសេវាសម្រាលកូន ឬលិខិតពិនិត្យសុខភាពក្រោយសម្រាល
- សេចក្តីចម្លងសំបុត្រកំណើតកូន
- គណនីធនាគារដៃគូដែលកំណត់ដោយ **ប.ស.ស.**
- ឯកសារចាំបាច់ផ្សេងទៀតតាមការកំណត់របស់ **ប.ស.ស.**។

**ប្រការ១០ .-**

ប្រាក់បំណាច់មាតុភាព ត្រូវផ្តល់ជូនតាមរូបមន្តដូចខាងក្រោម៖

**ប.ប.ម** = **៧០%** x **ប.ឈ.ម** x **៩០ថ្ងៃ**

**ប.ប.ម** ជាប្រាក់បំណាច់មាតុភាព

**ប.ឈ.ម** ជាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃដែលបានបង់ភាគទានរបស់សាមីជន។

# ជំពូកទី៤
# វិភាជន៍បូជាសព
## ផ្នែកទី១
## ការផ្តល់វិភាជន៍បូជាសព

**ប្រការ១១ .-**

វិភាជន៍បូជាសពផ្នែកថែទាំសុខភាព ត្រូវកំណត់ស្មើនឹង ២ ០០០ ០០០(ពីរលាន)រៀល។

## ផ្នែកទី២
## លក្ខខណ្ឌ

**ប្រការ១២ .-**

សិទ្ធិវន្តឬអ្នកចាត់ចែងបូជាសពសមាជិក **ប.ស.ស.** ដែលនៅមានសុពលភាពប្រើប្រាស់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ហើយទទួលមរណភាពដោយសារគ្រោះថ្នាក់ឬជំងឺក្រៅពីហានិភ័យការងារ មានសិទ្ធិទទួលបានវិភាជន៍បូជាសព។

ការផ្តល់វិភាជន៍បូជាសព មានប្រសិទ្ធភាពអនុវត្តចាប់ពីប្រកាសនេះចូលជាធរមាន។



ft.

## ផ្នែកទី៣
## បែបបទ និងនីតិវិធី

**ប្រការ១៣ .-**

សិទ្ធិវន្តឬអ្នកចាត់ចែងបូជាសព ត្រូវជូនដំណឹងមក **ប.ស.ស.** រយៈពេលយ៉ាងយូរ២(ពីរ)សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលមរណភាពរបស់សមាជិក **ប.ស.ស.** និងត្រូវបំពេញទម្រង់ទាមទារវិភាជន៍បូជាសព ដោយត្រូវភ្ជាប់មកជាមួយនូវ៖

- បណ្ណសមាជិក **ប.ស.ស.** របស់មរណជន
- សេចក្តីចម្លងសំបុត្រមរណភាព
- អត្តសញ្ញាណបណ្ណរបស់សិទ្ធិវន្តឬអ្នកចាត់ចែងបូជាសព
- គណនីធនាគារដៃគូដែលកំណត់ដោយ **ប.ស.ស.**
- ឯកសារចាំបាច់ផ្សេងទៀតតាមការកំណត់របស់ **ប.ស.ស.**។

## ជំពូកទី៥
## សហវិធាន

**ប្រការ១៤ .-**

ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ (**ប.ឈ.ម**) គឺជាផលចែកនៃប្រាក់ឈ្នួលជាប់ភាគទានសម្រាប់រយៈពេលជាក់ស្តែងមិនលើស៦(ប្រាំមួយ)ខែ មុនខែដែលមានបញ្ហាសុខភាពឬសម្រាល ចែកនឹង៣០(សាមសិប)ថ្ងៃ។

**ប្រការ១៥ .-**

ការកែសម្រួលវិភាជន៍បូជាសព ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

**ប្រការ១៦ .-**

**ប.ស.ស.** ត្រូវទូទាត់ប្រាក់បំណាច់មាតុភាព និងវិភាជន៍បូជាសព ក្នុងរយៈពេលមិនលើស១(មួយ)សប្តាហ៍ និងប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺក្នុងរយៈពេលមិនលើស២(ពីរ)សប្តាហ៍ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំរបស់សាមីជន។

ការផ្តល់តាវកាលិកជាសាច់ប្រាក់ជូនសមាជិក **ប.ស.ស.** ឬសិទ្ធិវន្ត ត្រូវធ្វើឡើងតាមទម្រង់ជាសេចក្តីសម្រេច ឬតាមទម្រង់នៃការផ្ទេរប្រាក់ទៅតាមគណនីផ្ទាល់របស់សាមីជន។

**ប្រការ១៧ .-**

សិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ ប្រាក់បំណាច់មាតុភាព និងវិភាជន៍បូជាសព ត្រូវអស់សុពលភាពត្រឹមរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចូលសម្រាកព្យាបាល ឬសម្រាលកូន ឬមរណភាពរបស់សាមីជន។

ករណីខកខានដោយប្រធានសក្តិ សាមីជនឬអ្នកតំណាងអាចទាមទារជាប្រាក់អវសិដ្ឋ។ ប្រាក់អវសិដ្ឋនេះត្រូវផ្តល់ជូនតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

**ប្រការ១៨ .-**

ការគណនាប្រាក់ឈ្នួលមធ្យមដែលកំណត់នៅក្នុងប្រការ១៤ នៃប្រកាសនេះ មានអានុភាពអនុវត្តចំពោះតែការគណនាតាវកាលិកសន្តិសុខសង្គមផ្នែកថែទាំសុខភាពប៉ុណ្ណោះ។



ffla.

**ប្រការ១៩ .-**

ទម្រង់នៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ ប្រាក់បំណាច់មាតុភាព វិភាជន៍បូជាសព និងលិខិតសុំអនុញ្ញាតច្បាប់ចេញដោយគ្រូពេទ្យសហគ្រាស គ្រឹះស្ថានត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស.**។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ២០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២១ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ២១
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ